# សមាហរណកម្មនៃបុរសខ្មែរដែលត្រូវបានជួញដូរ

និន្នាការនៃការជួញដូរ និងសេវាដែលមានស្រាប់

"ខ្ញុំចង់ឲ្យអង្គការនានា ព្រមទាំងរដ្ឋាភិបាលដឹងពីបទពិសោធន៍ដែលខ្ញុំ និងអ្នកដទៃទៀតបានជួប ដើម្បីឲ្យពួកគាត់អាចជួយពួកយើងនៅថ្ងៃណាមួយ។ សូមបញ្ជូនសាររបស់ខ្ញុំទៅដល់អង្គការនានា ព្រមទាំងរដ្ឋាភិបាល ទាំងក្នុង និងក្រៅប្រទេស ឲ្យពួកគាត់ជួយដល់ប្រជាជនកម្ពុជា [ដែលត្រូវបានជួញដូរ]" [1]

--ជនរួចជីវិតពីការជួញដូរទៅនាវានេសាទ

## រៀបរៀងដោយ *Kate Day* សម្រាប់ អង្គការ ហាការ កម្ពុជា
## ខែមិនា ឆ្នាំ២០១៥

[1] *Survivor quoted in Rebecca Surtees, In African waters. The trafficking of Cambodian fishers in South Africa (Geneva; Washington D.C.: IOM/NEXUS Institute, 2014), 155.*

# សេចក្តីសង្ខេប

បុរសនៅតែបន្តជាមុខសញ្ញាមួយភាគធំដែលត្រូវបានកំណត់ថាជាជនរងគ្រោះនៃការជួញដូរនៅក្នុងប្រទេសកម្ពុជា។ បើទោះបីជាមិនមានទិន្នន័យមូលដ្ឋានជាក់លាក់អំពីចំនួនជនរងគ្រោះ  នៅចន្លោះឆ្នាំ ២០១១ និងឆ្នាំ២០១៤ ក្នុងចំណោមជនរងគ្រោះដែលត្រូវបានជួយដោយកម្មវិធីប្រឆាំងការជួញដូរមនុស្សដំណាក់កាលទី ២ (គំរោង CTIP ទី២)មានបុរស ៥៩ ភាគរយ ហើយជាង ៨៨ ភាគរយ នៃជនរងគ្រោះទាំងនោះត្រូវបានជួយដោយអង្គការអន្តរជាតិផ្នែកទេសន្តរប្រវេសន៍ (IOM) ប្រចាំនៅប្រទេសកម្ពុជា។[២] ជាមធ្យមចាប់តាំងពីឆ្នាំ ២០១២ គំរោង CTIP ទី២ បានជួយបុរសរងគ្រោះនៃការជួញដូរ ចំនួន១៦០នាក់ក្នុងមួយឆ្នាំ។ មានបុរសរាប់ពាន់នាក់ទៀតដែលទំនងជាមិនទាន់ត្រូវបានគេស្គាល់អត្តសញ្ញាណ ប៉ុន្តែនៅតែមានការខ្វះសេវារួមបញ្ចូល រឺសមាហរណកម្មសម្រាប់បុរស ជាពិសេសបុរសពេញវ័យ នៅមិនទាន់គ្រប់គ្រាន់នៅឡើយ។ ការសិក្សាមួយក្នុងឆ្នាំ២០១៣ លើបុរសរងគ្រោះចំនួន៧៨នាក់ក្នុងចំណោមបុរសដែលត្រូវបានជួញដូរនៅក្នុងមហាអនុតំបន់ទន្លេមេគង្គ (ក្នុងនោះមានបុរសខ្មែរចំនួន២៧នាក់) បានរកឃើញថា មានតែបុរសចំនួន១០នាក់ប៉ុណ្ណោះដែលទទួលបានជំនួយពេញលេញ ។[៣] ការសិក្សាថ្មីមួយអំពី កម្មករនេសាទជនជាតិខ្មែរដែលត្រូវបានជួញដូរ បានរកឃើញថា បុរសភាគច្រើនបានទទួលជំនួយផ្នែកច្បាប់ ប៉ុន្តែពួកគេទទួលបានជំនួយផ្នែកផ្សេងទៀតតិចតួចប៉ុណ្ណោះ ទោះបីជាជនរួចជីវិតទាំងអស់នោះខិតខំស្វែងរកការគាំទ្រយ៉ាងសកម្មក៏ដោយ។[៤]

គោលបំណងនៃការស្រាវជ្រាវនេះ គឺដើម្បីជូនដំណឹងដល់ក្រុមអ្នកផ្តល់សេវាដែលមានបំណងបំពេញចន្លោះខ្វះខាតខាងលើនេះ ក្នុងការផ្តល់សេវាដល់បុរសរងគ្រោះបន្ទាប់ពីពួកគេរួចជីវិតពីការជួញដូរ។

[២] *Data supplied to author. CTIP II data is for the period October 2011-December 2014, and IOM Cambodia data for the period 2011-2014.*

[៣] *Rebecca Surtees, After trafficking: Experiences and challenges in (re)integration in the Greater Mekong Sub-region (Bangkok: UNIAP/NEXUS Institute, 2013), 110.*

[៤] *Rebecca Surtees, In African waters. The trafficking of Cambodian fishers in South Africa (Geneva, Washington D.C.:*

ការស្រាវជ្រាវនេះយោងតាមការវិភាគទៅលើឯកសារដែលមានស្រាប់ និងទិន្នន័យដែលបានមកពីក្រុមអ្នកផ្តល់សេវា ដោយបូកបញ្ចូលទាំងការធ្វើបទសម្ភាសន៍ជនបង្គោលដែលដឹងព័ត៌មានចំនួន៣៣នាក់ និងបទសម្ភាសន៍ជាក្រុមជាមួយជនរួចជីវិតពីការជួញដូរចំនួនដប់ប្រាំបីនាក់ ។

របាយការណ៍នេះបានគ្របដណ្តប់លើប្រធានបទដូចខាងក្រោម:

- និន្នាការក្នុងការជួញដូរបុរសកម្ពុជាដោយផ្តោតលើការជួញដូរមនុស្សទៅនាវានេសាទ
- តម្រូវការសមាហរណកម្មនៃជនរួចជីវិត
- សមាហរណកម្មបុរស និងសេវាកម្មដែលមានស្រាប់នៅក្នុងប្រទេសកម្ពុជា

ការស្រាវជ្រាវនេះជួយបំពេញចន្លោះខ្វះខាតនៅក្នុងការស្រាវជ្រាវលើនិន្នាការក្នុងការជួញដូរបុរសកម្ពុជា។ វាគជាការសិក្សារមួយបន្ថែមលើការសិក្សារពីរ រឺក៏បីប៉ុណ្ណោះដែលធ្វើឡើងអំពីសមាហរណកម្មសម្រាប់ជនរួចជីវិតពីការជួញដូរទៅនាវានេសាទ។

# ចំនុចសំខានៗនៃការរកឃើញ

## និន្នាការក្នុងការជួញដូរបុរស[៥]

បុរសខ្មែរត្រូវបានជួញដូរទៅក្នុងវិស័យខុសៗគ្នា ហើយជាទូទៅភាគច្រើនគឺ វិស័យនេសាទ សំណង់ កសិកម្ម ការងាររោងចក្រ និងសុំទាន។ ជនរួចជីវិតដែលត្រូវបានគេកំណត់អត្តសញ្ញាណ ភាគច្រើនគឺវិលត្រឡប់មកពីប្រទេសថៃ បន្ទាប់មកគឺប្រទេសឥណ្ឌូនេស៊ុី វៀតណាម និងប្រទេសម៉ាឡេស៊ី។ ជនរួចជីវិតទាំងនោះភាគច្រើនគឺមកពីតំបន់ដាច់ស្រយាល និងជនបទ។ ពួកគេកម្រទទួលបានការសិក្សាលើសពីកំរិតថ្នាក់អប់រំបឋមសិក្សាណាស់។ ពួកគេស្ទើរតែទាំងអស់គឺជាអ្នករកស៊ីចិញ្ចឹមគ្រួសារ ជាហេតុនាំឲ្យការផ្លាស់ទីមានកំរិតខ្ពស់ដោយសារតែពួកគេត្រូវធ្វើដំណើរទៅស្វែងរកការងារធ្វើ។ ភាគច្រើនពួកគេមានប្រភពដើមមកពីខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម បាត់ដំបង កំពង់ធំ ឧត្តរមានជ័យ សៀមរាប និងខេត្តស្វាយរៀង។ ជនរងគ្រោះមួយចំនួនតូចត្រូវបានរកឃើញថាមកពីខេត្តតំបន់ភាគឦសាន។ ជារួម ជនរួចជីវិតមានប្រភពមកពីគ្រប់តំបន់ទូទាំងប្រទេស ហើយពាក់កណ្ដាលនៃពួកគាត់ទាំងអស់ត្រូវបាន “ចាត់ជាក្រុមមនុស្ស” ដែលមកពីភូមិតែមួយ ព្រោះក្នុងចំណោមពួកគាត់ យ៉ាងហោចណាស់ក៏មានជនរងគ្រោះម្នាក់ដែរ ដែលមកពីភូមិជាមួយគ្នា។

៥ *International Labour Organisation (ILO) and Asian Research Centre for Migration, Institute of Asian Studies, Chulalongkorn University, Employment practices and working conditions in Thailand’s fishing sector, (Bangkok: ILO, 2013), 68.*

## ការជួញដូរមនុស្សទៅនាវានេសាទ

ការជួញដូរទៅឧស្សាហកម្មនេសាទត្រីនៅក្នុងតំបន់ មានចំនួនច្រើនជាងពាក់កណ្តាលនៃជនរងគ្រោះជាបុរសដែលត្រូវបានកំណត់អត្តសញ្ញាណ។ ដោយហេតុផលនេះ ការជួញដូរមនុស្សទៅនាវានេសាទត្រូវបានរំលេចឡើងជាពិសេសនៅក្នុងរបាយការណ៍នេះ។ អ្នកនេសាទដែលត្រូវបានគេជួញដូរចំនួន ជាង ៣០០នាក់ បានត្រឡប់មកវិញនៅចន្លោះឆ្នាំ២០១០ និងឆ្នាំ២០១៤ ទោះបីជាវាទំនងថាជនរងគ្រោះជាច្រើនទៀតមិនត្រូវបានកំណត់អត្តសញ្ញាណក៏ដោយ។ ការសិក្សាមួយស្តីពីឧស្សាហកម្មនេសាទរបស់ប្រទេសថៃ បានរកឃើញថាចំនួនប្រាំបួនភាគរយនៃអ្នកនេសាទជាជនជាតិខ្មែរកំពុងក្លាយជាជនរងគ្រោះនៃការបង្ខិតបង្ខំលើកំលាំងពលកម្ម។[៥]

បើគិតត្រឹមតែអត្រាតួលេខនៃក្រុមអ្នកនេសាទដែលចំណាយពេលយូរនៅលើទូកនេសាទតែម្យ៉ាងគឺមានកម្រិតខ្ពស់ជាងវិស័យដទៃទៀតរួចទៅហើយ។ ការសិក្សាមួយស្តីពីប្រជាជនកម្ពុជាដែលត្រូវបាននិរទេសពីប្រទេសថៃ បានរកឃើញថា ម្នាក់ក្នុងចំណោមអ្នកនេសាទ៥នាក់ដែលត្រូវបានគេនិរទេស អាចជាមនុស្សដែលត្រូវបានគេជួញដូរ។[៦]

ទំនងជាមានប្រជាជនកម្ពុជារាប់ម៉ឺននាក់កំពុងធ្វើការនៅលើទូកនេសាទថៃ។ ប្រជាជនកម្ពុជាជាង ២២,០០០ នាក់បានចុះឈ្មោះជាផ្លូវការ[៧] ប៉ុន្តែចំនួនពិតប្រាកដគឺទំនងជាខ្ពស់ជាងនេះ។ អង្គការពលកម្មអន្តរជាតិ (ILO) បានប៉ាន់ប្រមាណថាប្រជាជនកម្ពុជាមានចំនួន ៤០ ភាគរយនៃអ្នកនេសាទនៅកំពង់ផែសំខាន់ៗទាំងបួនរបស់ប្រទេសថៃ។[៨] ការប៉ាន់ប្រមាណអំពីចំនួនប្រជានេសាទនៅលើនាវានៅប្រទេសថៃមានចំនួនប្រហែលពី ១០០,០០០ ទៅ ១៤៣,០០០ នាក់។ [៩]លទ្ធផលនៃការសិក្សារខាងលើ បានបង្ហាញថា មួយចំនួនធំនៃកម្មករនេសាទកម្ពុជាទំនងជាជនរងគ្រោះនៃការជួញដូរ។

[៥]*International Labour Organisation (ILO) and Asian Research Centre for Migration, Institute of Asian Studies, Chulalongkorn University, Employment practices and working conditions in Thailand’s fishing sector, (Bangkok: ILO, 2013), 68.*

[៦] *United Nations Action for Cooperation Against Trafficking in Persons (UN-ACT), Migration experiences of Cambodian workers deported from Thailand in 2009, 2010 & 2012 Poipet, Cambodia, (Bangkok: UN-ACT, 2015), 49.*

[៧] *Data from ILO, Bangkok.*

[៨] *“The workers were sampled in proportion to size of the total population by nationality in the occupation.” ILO and Asian Research Centre for Migration, 2013, 5.*

[៩] *See discussion in ILO and Asian Research Centre for Migration, 2013, p. 4-5.*

ការជួញដូរមនុស្សភាគច្រើនកើតឡើងនៅពេលដែលបុរសធ្វើចំណាកស្រុកដោយស្ម័គ្រចិត្តទៅតាមច្រកមិនស្របច្បាប់ ដោយគ្មានឯកសារធ្វើដំណើរ ហើយក្រោយមកត្រូវបានមេខ្យល់បោកបញ្ឆោតដោយបញ្ជូនពួកគេទៅទូកនេសាទ ឬលក់ពួកគេអោយអ្នកគ្រប់គ្រងនាវានាវា។ ករណីលើកលែងមួយចំពោះនិន្នាការនេះ គឺជាករណីនៃក្រុមហ៊ុន Giant Ocean International Fishery Co., Ltd (Giant Ocean)ដែលជាទីភ្នាក់ងារជ្រើសរើសពលករដែលមានអាជ្ញាប័ណ្ណដែលបានជួញដូរប្រជាជនកម្ពុជាប្រមាណជា ៧០០នាក់ ទៅកាន់នាវានេសាទនៅក្នុងប្រទេសជាច្រើន។[១០] ភ្នាក់ងារផ្តល់ជំនួយសង្រ្គោះនានាបានធ្វើការព្យាករថ មនុស្សប្រហែល ២០០ នាក់នៃជនរងគ្រោះទាំងនេះត្រូវបានត្រឡប់មកវិញ ប៉ុន្តែមនុស្សជាច្រើនរយនាក់នៅតែបាត់ខ្លួន។

អ្នកនេសាទកម្ពុជាដែលត្រូវបានជួញដូរ តែងទទួលរងនូវបទពិសោធន៍នៃ ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរ លើរាងកាយ និងផ្លូវចិត្ត ផលប៉ះពាល់ដោយសារអាកាសធាតុ ការងារប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ កង្វះអាហារូបត្ថម្ភ និងការថែទាំសុខភាព និងស្ថានភាពរស់នៅដែលមិនមានសុវត្ថិភាព។ ភាគច្រើនមិនទទួលបានប្រាក់កម្រៃ រឺទទួលបានតិចតួចបំផុត។ ការសិក្សាថ្មីមួយធ្វើឡើងដោយ IOM និង***London School of Hygiene and Tropical Medicine*** លើសុខភាព និងការជួញដូរមនុស្ស បានរកឃើញថា សំណាកនៃអ្នកនេសាទដែលត្រូវបានគេជួញដូរចំនួន២១៩នាក់ បានធ្វើការជាមធ្យម ១៩.៥ ម៉ោងក្នុងមួយថ្ងៃ។[១១] ពីរភាគបីនៃអ្នកទាំងនោះបានទទួលរងគ្រោះដោយអំពើហិង្សាលើរាងកាយ។ ជនរងគ្រោះ១៦ នាក់ត្រូវបានបង្ខំអោយទទួលទានថ្នាំញៀន និងបួននាក់បានរាយការណ៍ថាបានទទួលរងគ្រោះដោយអំពើហិង្សាផ្លូវភេទ។[១២] របាយការណ៍ស្តីពីបទពិសោធន៍នៃអ្នកនេសាទដែលត្រូវបានគេជួញដូរចំនួន៤៩នាក់ បានរកឃើញថា ៥៩ ភាគរយបានធ្វើសាក្សីថាមានការសម្លាប់មនុស្សដោយអ្នកគ្រប់គ្រងនាវា។[១៣] បុរសទាំងនោះភាគច្រើនជាប់ឃុំនៅលើនាវារយៈពេលច្រើនឆ្នាំ៖ ការសិក្សាខាងលើចំពោះសំណាកអ្នកនេសាទទាំង២១៩ បានរកឃើញថា ស្ទើរតែ៥០ភាគរយនៃពួកគេរស់នៅក្នុងស្ថានភាពនៃការជួញដូរនេះរយៈ ពេលច្រើនជាងពីរឆ្នាំ។ ។[១៤] ហើយមនុស្សមួយចំនួនទៀតត្រូវបានគេជួញដូររហូតដល់ទៅជាង១០ឆ្នាំ។

បន្ទាប់ពីការរត់គេចខ្លួន វាគឺជារឿងទូទៅបំផុតដែលជនរងគ្រោះបានចំណាយពេលវេលានៅក្នុងការឃុំឃាំង។ អ្នកផ្សេងទៀតបានទទួលរងការកេងប្រវ័ញ្ចបន្ថែមទៀត ឬត្រូវបានគេជួញដូរម្តងទៀតមុនពេលដែលពួកគេបានវិលត្រឡប់មកផ្ទះវិញនៅទីបំផុត។

## តម្រូវការរបស់ជនរួចជីវិត

**តម្រូវការផ្នែកសេដ្ឋកិច្ច** គឺមានសារៈសំខាន់បំផុតសម្រាប់ជនរួចជីវិតភាគច្រើន។ ពួកគាត់ភាគច្រើនគ្មានជំនាញក្នុងការប្រកបរបរចិញ្ចឹមជីវិត ហើយពួកគេត្រឡប់ទៅកាន់តំបន់ជនបទដាច់ស្រយាលដែលជាកន្លែង មានភាពពិបាកជាខ្លាំងសម្រាប់ពួកគាត់ក្នុងការបង្កើតស្ថេរភាពប្រាក់ចំណូលពេញមួយឆ្នាំ។ ដូច្នេះការធ្វើចំណាកស្រុកសារជាថ្មីគឺជារឿងដែលតែងតែកើតមានឡើង។ ការជួញដូរច្រើននាំអោយមានបញ្ហាហិរញ្ញវត្ថុកាន់តែធ្ងន់ធ្ងរបន្ថែមទៀតសំរាប់ជនរួចជីវិតទាំងនោះ។ ពួកគាត់ខ្លះមានបំណុលគ្រួសាររហូតដល់១០០០ ដុល្លារសហរដ្ឋអាមេរិក។ បន្ទុកទាំងនេះបង្កើតអោយមានភាពតានតឹងផ្លូវចិត្ត និងបង្អាក់ជនរួចជីវិតមិនអោយពួកគាត់មានលទ្ធភាពស្វែងរកការគាំទ្រ។

ប្រជាជនខ្មែរដែលរស់រានមានជីវិតពីការជួញដូរ ជាញឹកញាប់ពួកគេមានសេចក្តីត្រូវការផ្នែកសុខភាពជានិច្ច។ អ្នករស់រានមានជីវិតបានរាយការណ៍ថា ពួកគាត់បានរងការឈឺចុកចាប់ក្បាលរ៉ាំរ៉ៃ ខ្វះជីវជាតិ ឈឺខ្នង ឈឺសួត និងបញ្ហាពាក់ព័ន្ធនឹងការរំលាយអាហារ រួមទាំងជំងឺផ្សេងៗទៀត។ ការស្ទង់មតិជាមួយជនរួចជីវិត បានរកឃើញថា សុខភាពរាងកាយគឺជាកង្វល់រួមមួយ។ ប្រហែលជាពីរភាគបីនៃបុរសដែលបានឆ្លើយតបចំពោះការស្ទង់មតិ ពួកគេប្រាថ្នាចង់ជួបជាមួយគ្រូពេទ្យ។ [១៥]

[១០] Police estimated that more than 700 men were sent abroad by Giant Ocean. Surtees, 2014, 17.

[១១] Cathy Zimmerman et al., "Health and human trafficking in the Greater Mekong Subregion. Findings from a survey of men women and children in Cambodia, Thailand and Viet Nam, International Organization for Migration and London School of Hygiene and Tropical Medicine, Cambodia results," (presentation at STEAM launch held by London School of Hygiene and Tropical Medicine and IOM Cambodia, Phnom Penh, 18 November 2014).

[១២] Data provided by London School of Hygiene and Tropical Medicine and IOM Cambodia, 2014.

[១៣] UNIAP, Exploitation of Cambodian men at sea: Facts about the trafficking of Cambodian men onto Thai fishing boats, SIREN series CB-03, (Bangkok: UNIAP, 2009).

[១៤] Zimmerman et al, 2014.

[១៥] Ibid.

**សុខភាពផ្លូវចិត្តអន់ខ្សោយខ្លាំង**គឺជារឿងដែលកើតឡើងទូទៅនៅក្នុងចំណោមជនរួចជីវិតទាំងអស់នោះ។ នៅក្នុងការសិក្សាមួយលើសុខភាព និងការជួញដូរមនុស្ស ធ្វើឡើងដោយ IOM និង ***London School of Hygiene and Tropical Medicine*** រកឃើញថា ៦២ភាគរយនៃបុរសពេញវ័យដែលត្រូវបានជួញដូរ បានបង្ហាញរោគសញ្ញានៃជំងឺធ្លាក់ទឹកចិត្ត ៥៤ភាគរយមានការថប់បារម្ភ និង ៤៦ភាគរយមានជំងឺបាក់ស្បាត។[១៦] ភ្នាក់ងារផ្តល់សេវបានរំឭកអំពីករណីនៃជនរួចជីវិតថាបានទទួលរងការប៉ះទង្គិចផ្លូវចិត្ត មានឥរិយាបថបង្កគ្រោះថ្នាក់ ប្រើសារធាតុញៀន និងបញ្ហាការចងចាំ។

ជនរួចជីវិតលទ្ធភាពដែលជនរួចជីវិតអាចទទួលបានការគាំទ្រពី សង្គម អាចនឹងមានភាពស្មុគស្មាញដោយសារហេតុផលជាច្រើន។ ជនរួចជីវិតដែលត្រឡប់មកវិញជាញឹកញាប់មានអារម្មណ៍ថា មានកំហុស ឬអាម៉ាស់ ខ្លាចមានការរើសអើង ឬបារម្ភពីបញ្ហាក្នុងការសម្របខ្លួនទៅនឹងការផ្លាស់ប្តូរបរិយាកាសជុំវិញខ្លួន និងទំនាក់ទំនង។

សមាជិកគ្រួសារជនរងគ្រោះ អាចត្រូវបានចាត់ទុកថាជា "**ជនរងគ្រោះបន្ទាប់**" នៅពេលពួកគេមានបញ្ហាដែលជាលទ្ធផលបានមកពីបទពិសោធន៍របស់ជនរងគ្រោះដែលត្រូវបានគេជួញដូរ ។ សមាជិកគ្រួសារអាចត្រូវរងផលប៉ះពាល់ដោយប្រយោលដោយសារបញ្ហាសុខភាពឬបញ្ហាសេដ្ឋកិច្ចរបស់ជនរងគ្រោះ ឬផលប៉ះពាល់ដោយផ្ទាល់ពីអាកប្បកិរិយាណាមួយរបស់ជនរងគ្រោះដែលប្រឆាំងនឹងសង្គមជនរួចជីវិតដែលសមាជិកគ្រួសារនោះត្រូវដោះស្រាយ។ សមាជិកគ្រួសារក៏មានតម្រូវការផ្នែក
សេដ្ឋកិច្ច សុខភាព និងតម្រូវការផ្សេងទៀតដែលពួកគេគួរតែបង្ហាញចេញដើម្បីខ្លួនឯងផ្ទាល់ និងដើម្បីជួយអោយពួកគាត់អាចជួយគាំទ្រដល់ជនរួចជីវិតនោះបាន។

[១៦] *Ibid.*

ជនរងគ្រោះជាច្រើន**ត្រូវការកន្លែងស្នាក់នៅជាបណ្តោះអាសន្ន**នៅពេលដែរពួកគេត្រឡប់មកវិញ។ មានត្រឹមតែមួយចំនួនតូចទេដែរត្រូវការជំនួយជាមួយនឹងការស្នាក់នៅរយៈពេលវែង។ ជនរងគ្រោះជាច្រើនត្រូវការ**ជំនួយផ្នែកច្បាប់**ដើម្បីទាមទាសំណង ឬដាក់ពាក្យបណ្តឹងប្រឆាំងអ្នកជួញដូរពួកគេ។ ក្នុងករណីខ្លះជនរងគ្រោះមួយចំនួនមានការភ័យខ្លាចចំពោះសុវត្ថិភាពរបស់ពួកគេ ហើយអ្នកខ្លះជ្រើសរើសមិនអោយមានការលាតត្រដាងពីបទពិសោធន៍ជួញដូរដែលពួកគេទទួលរង ដូច្នេះហើយពួកគេមានតម្រូវការផ្នែក**សន្តិសុខ និងភាពឯកជន**របស់ពួកគេ។

## សមាហរណកម្មដែលទទួលបានជោគជ័យ និងសេវាកម្មដែលមានស្រាប់នៅក្នុងប្រទេសកម្ពុជា

ដូចដែលបានកំណត់ដោយ Surtees ការធ្វើសមាហរណកម្ម  គឺជាដំណើរការនៃការជាសះស្បើយឡើងវិញ និងការត្រឡប់ទៅរស់នៅក្នុងប្រពន្ធសេដ្ឋកិច្ច និងក្នុងសង្គមឡើងវិញ បន្ទាប់ពីទទួលរងបទពិសោធន៍នៃការជួញដូរមនុស្ស។ សមាហរណកម្មសំដៅលើទាំងការតាំងទីលំនៅក្នុងបរិយាកាសដែល

មានសុខសុវត្ថិភាព  ការទទួលបាននូវការរស់នៅដែលមានបទដ្ឋានសមហេតុផល សុខុមាលភាពផ្លូវចិត្ត និងផ្លូវកាយ ឱកាសសម្រាប់ការអភិវឌ្ឍន៍ផ្ទាល់ខ្លួន ការអភិវឌ្ឍន៍សង្គម និងសេដ្ឋកិច្ច  ព្រមទាំងការទទួលបាននូវការគាំទ្រផ្នែកសង្គម និងផ្លូវចិត្ត។ ជនដែលត្រូវបានគេជួញដូរអាចជ្រើសរើសក្នុងការរស់នៅក្នុងសហគមន៍របស់ពួកគាត់ (សមាហរណកម្ម) រឺនៅក្នុងសហគមន៍ថ្មីមួយ(ការរួមបញ្ចូល)។[១៧]

ការរួមបញ្ចូល រឺការធ្វើសមាហរណកម្មដែរពោរពេញដោយជោគជ័យគឺពាក់ព័ន្ធទៅនឹងផ្នែកជាច្រើន ដែលមិនពឹងផ្អែកតែលើជនរួចជីវិតនោះទេ ប៉ុន្តែក៏ពឹងផ្អែកលើបរិយាកាសខាង ក្រៅដែរ។ ហេតុនេះហើយបានជាដំណើរការនេះមានភាពស្មុគស្មាញយ៉ាងខ្លាំង ហើយងាយនឹងរាំងស្ទះ ហើយដោយសារការជួបនូវឧបសគ្គផ្សេងៗ ជាញឹកញាប់វាត្រូវការពេលជាច្រើនឆ្នាំ។ កត្តាសំខាន់ក្នុងការធ្វើសមាហរណកម្ម (រឺការរួមបញ្ចូល)ដោយជោគជ័យ គឺត្រូវដកចេញនូវកត្តានៃភាពងាយរងគ្រោះដំបូងដែលបានធ្វើអោយជនរងគ្រោះធ្លាក់ទៅក្នុងការជួញដូរ។

បញ្ហាយេនឌ័រគួរត្រូវបានពិចារណាផងដែរនៅក្នុងការរួមបញ្ចូល រឺការធ្វើសមាហរណកម្ម។ ការយល់ឃើញអំពីយេនឌ័រ គឺមានសក្តានុពលធ្វើអោយជនរួចជីវិតងាយធ្លាក់ទៅក្នុងការជួញដូរ ប៉ះ

[១៧] *Surtees, 2013, 38.*

ពាល់ដល់តម្រូវការរបស់ពួកគេក្រោយការជួញដូរ សេវាដែលអាចរកបាន ព្រមទាំងប៉ះពាល់ដល់ឆន្ទៈរបស់ជនរួចជីវិតក្នុងការទទួលយកសេវាទាំងនេះ។

## សេវាបច្ចុប្បន្ន បញ្ហាប្រឈម និងឱកាស

**ទិដ្ឋភាពទូទៅនៃការផ្តល់សេវានាពេលបច្ចុប្បន្ន** - ទោះបីជារដ្ឋាភិបាលកម្ពុជាមានក្រុមការងារចុះផ្តល់ការគាំទ្រសម្រាប់បុរសដែលត្រូវបានគេជួញដូរ ប៉ុន្តែរដ្ឋាភិបាលជួបនូវការខ្វះថវិការ មានន័យថាភាគច្រើននៃបន្ទុកសមាហរណកម្មនេះ ត្រូវធ្លាក់ទៅលើអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការអន្តរជាតិ។ បច្ចុប្បន្នតួនាទីរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MoSVY) និងនាយកដ្ឋានសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (DoSVY) នៅក្នុងការរួមបញ្ចូល រឺការធ្វើសមាហរណកម្មហាក់ដូចជាមានកម្រិត ត្រឹមតែការបញ្ជូន និងការបំពេញក្រដាសស្នាម ចំណែកឯការសួរសុខទុក្ខអតិថិជនវិញរដ្ឋាភិបាលអាចធ្វើបានប្រសិនបើមានអង្គការក្រៅរដ្ឋាភិបាលណាមួយអាចបង់លើការចំណាយសម្រាប់សកម្មភាពនេះប៉ុណ្ណោះ។

យ៉ាងហោចណាស់មានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការអន្តរជាតិចំនួនដប់ពីរដែលផ្តល់នូវជំនួយលើការរួមបញ្ចូល រឺសមាហរណកម្មតាមបែបផែនមួយចំនួន ជូនដល់បុរសដែលត្រូវបានគេជួញដូរ។ សេវានេះមានលក្ខណៈផ្អែកលើសហគមន៍ស្ទើទាំងស្រុង ក្នុងប្រទេសកម្ពុជាមានមណ្ឌលសម្រាប់ជួយដល់បុរសរងគ្រោះដោយការជួញដូរតែមួយគត់។ ភាគច្រើននៃការផ្តល់ជំនួយនេះ បានកើតឡើងនៅក្នុង សហគមន៍ដែលជនរួចជីវិតនោះធ្លាប់រស់នៅ។

មាន ករណីតិចតួចប៉ុណ្ណោះដែលត្រូវបានគាំទ្រលើការធ្វើសមាហរណកម្មទៅកន្លែងផ្សេង។

**មូលនិធិ-** មូលនិធិសម្រាប់ជំនួយការធ្វើ(សមាហរណកម្ម) រួមបញ្ចូល ជាចម្បងគឺបានមកពីកម្មវិធីរបស់ USAID គំរោង CTIP II ដែលមានបូករួមទាំងម្ចាស់ជំនួយមួយចំនួនបន្ថែមទៀត។ មូលនិធិគឺជាធម្មតាមានចំនួនប្រហែល៨០០ទៅ១០០០ដុល្លាសហរដ្ឋអាមេរិកសម្រាប់រាល់ជំនួយក្នុងការធ្វើ(សមាហរណកម្ម)ការរួមបញ្ចូលអតិថិជនម្នាក់។ អ្នកផ្តល់សេវាមួយចំនួនបានប៉ាន់ប្រមាណថាដើម្បីអោយការគាំទ្រ អាចធ្វើទៅបានពេញលេញ គេត្រូវការទឹកប្រាក់ចំនួន២០០០ដុល្លាសហរដ្ឋអាមេរិក។

## ការកំណត់អត្តសញ្ញាណ

មានអង្គការមួយចំនួនដែលស្វែងរក ឬធ្វើការពិនិត្យមើលដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះ នៅប៉ោយប៉ែត និងខេត្តកោះកុង តទោះជាយ៉ាងណា ក៏ការពិនិត្យនោះមិនទាន់មានផែនការត្រឹមត្រូវនៅឡើយ ដោយការពិនិត្យនោះកើតឡើងនៅពេលដែលអ្នកផ្តល់សេវាមានធនធានតែប៉ុណ្ណោះ។ គ្មានការស្វែងរកយ៉ាងសកម្មដើម្បីរកជនរងគ្រោះ ប្រទេសគោលដៅទេ បើទោះបីជាមើលឃើញថាប្រជាជនកម្ពុជាអាចនឹងត្រូវបានជាប់គាំងនៅលើកោះ ឬកំពង់ផែបរទេសក៏ដោយ។ មិនមានបញ្ជីផ្សព្វផ្សាយជនបាត់ខ្លួនទេ បើទោះបីជាជនរងគ្រោះរាប់រយនាក់នៃក្រុមហ៊ុនមហាសមុទ្រយក្ស (Giant Ocean) អាចនឹងមិនត្រូវបានរាប់បញ្ចូលក៏ដោយ។ ជាលទ្ធផល ចំនួននៃ ជនរងគ្រោះដែលត្រូវបានកំណត់អត្តសញ្ញាណ គឺមានកម្រិតទាបខ្លាំងណាស់ បើប្រៀបធៀបទៅនឹងទំហំនៃបញ្ហាដែលមាននេះ។

## ជំនួយជាមូលដ្ឋាន

យ៉ាងហោចណាស់មានអង្គការចំនួនប្រាំពីរមានផ្តល់ជំនួយជាមូលដ្ឋាន (ដូចជាការពិនិត្យសុខភាព កញ្ចប់ម្ហូបអាហារ និងថវិការសម្រាប់ធ្វើដំណើរ) ដល់ជនរងគ្រោះដែលត្រូវបានកំណត់អត្តសញ្ញាណបាន នៅពេលដែលពួកគេវិលត្រឡប់មកវិញ។ អង្គការខ្លះបង់ប្រាក់សម្រាប់ការស្នាក់នៅផ្ទះសំណាក់រយៈពេលពីរបីថ្ងៃ។ មានមណ្ឌលតែមួយគត់នៅប្រទេសកម្ពុជាដែលផ្តល់ជម្រកដល់បុរសរងគ្រោះពីការជួញដូរ គឺមជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ (CCPCR) នៅខេត្តស្វាយរៀង។ អង្គការអន្តរជាតិ IOM ឆាប់ៗនេះនឹងបើកមណ្ឌលស្នាក់នៅបណ្តោះអាសន្នមួយនៅទីក្រុងភ្នំពេញ។

**ការបញ្ជូន**- បច្ចុប្បន្ននេះពុំមានប្រព័ន្ធបញ្ជូនជាផ្លូវការនោះទេ។ ជនរងគ្រោះជាច្រើននាក់មិនដែលត្រូវបានបញ្ជូនដើម្បីទៅទទួលសេវា(សមាហរណកម្ម) រួមបញ្ចូលនោះទេ ប្រហែលជាមកពីអ្នកឆ្លើយតបដំបូង មិនបានដឹងពីសារៈសំខាន់នៃការគាំទ្រ រឺក៏មិនដឹងថាមានជម្រើសនៃការបញ្ជូនបន្ត។ ជនរួចជីវិតដទៃទៀតត្រូវបានបញ្ជូនទៅអង្គការដែលផ្តល់នូវជំនួយប្រភេទតែមួយគត់ (ដូចជាជំនួយផ្នែកច្បាប់ ឬ ការបណ្តុះបណ្តាលវិជ្ជាជីវៈ)។ ជនរួចជីវិតទាំងនេះកម្រត្រូវបានបញ្ជូនទៅទទួលការគាំទ្រលើតម្រូវការផ្សេងទៀតរបស់ពួកគេណាស់។ ជនរួចជីវិតដែលត្រូវបានបញ្ជូនដើម្បីទទួលបានការគ្រប់គ្រងករណីរយៈពេលវែងបានទទួលការគាំទ្រដ៏ពេញលេញ
បំផុត។ ផ្តល់ការបណ្តុះបណ្តាលដល់អ្នកឆ្លើយតបដំបូង និងអ្នកផ្តល់ជំនួយទាំងអស់ដើម្បីបញ្ជូនជនរួចជីវិតទៅអង្គការដែលផ្តល់សេវាគ្រប់គ្រងករណី ដែលអាចជួយដោះស្រាយចន្លោះខ្វះខាតដែលមានក្នុងពេលបច្ចុប្បន្ននេះ។

## ការសម្របសម្រួលនៃការជួយសង្គ្រោះ

ការសម្របសម្រួលនៃការផ្តល់សេវា សម្រាប់បុរសដែលត្រូវបានគេជួញដូរគឺមានតិចតួចបំផុត។ នៅឆ្នាំ ២០១៤ អង្គការអន្តរជាតិ IOM បានផ្តួចផ្តើមអោយកិច្ចប្រជុំរវាងអ្នកផ្តល់សេវាដើម្បីពិភាក្សាអំពីការ

ជួយសង្គ្រោះដល់ជនរួចជីវិតនៅពេលពួកគេវិលត្រឡប់មកវិញ។ មិនមានការជួបជុំជាទៀងទាត់ដើម្បីពិភាក្សាអំពីការគាំទ្របន្តចំពោះបុរសដែលគេជួញដូរនោះទេ ហើយក៏មិនមានការសម្របសម្រួលក្នុងការប្រមូលទិន្នន័យដែរ។

## ជំនួយផ្នែកច្បាប់

យ៉ាងហោចណាស់មានអង្គការចំនួនបួនផ្តល់ជំនួយផ្នែកច្បាប់។ អង្គការទាំងនេះតំណាងឱ្យជនរងគ្រោះជាង១៥០នាក់នៅក្នុងសំណុំរឿងប្រឆាំងនឹងក្រុមហ៊ុន មហាសមុទ្រយក្ស (Giant Ocean) ដែលនាំឱ្យជនជាប់ចោទតែវ៉ាន់ចំនួនប្រាំមួយនាក់ត្រូវបានផ្តន្ទាទោស។ អង្គការទាំងនេះបានទទួលយកសំណុំរឿងប្រឆាំងនឹងមេខ្យល់ជនជាតិខ្មែរផងដែរ ដែលបានជួញដូរបុរសទាំងអស់

នោះ។ ទោះជាយ៉ាងណា ករណីតុលាការដំណើរការទៅយ៉ាងយឺតយ៉ាវបំផុត។ សូម្បីតែនៅពេលដែលជនល្មើសត្រូវបានផ្តន្ទាទោស ក៏ជនរងគ្រោះកម្រនឹងទទួលបានសំណងណាស់។ ករណីផ្នែកច្បាប់នៅក្រៅប្រទេស គឺកម្រមានខ្លាំងណាស់ទោះបីជាការពិតដែលថាជនល្មើសភាគច្រើនស្ថិតនៅក្នុងប្រភេទរឿងនេះ ។

**ការតពិនិត្យសុខភាព**អាចរកបានសម្រាប់ជនរងគ្រោះភាគច្រើននៅពេលពួកគេត្រូវបានកំណត់អត្តសញ្ញាណជាលើកដំបូង។ ទោះជាយ៉ាងណាក៏ដោយ អ្នកផ្តល់សេវាបានរំឭកប្រាប់ថាមានករណីតិចតួចណាស់នៅក្នុងការដែលជនរួចជីវិតបានទទួលជំនួយជាបន្តសំរាប់បញ្ហាសុខភាព។ ចំណុចនេះហាក់បីដូចជាមិនធម្មតា នៅពេលដែលមានករណីសិក្សា និងការសិក្សាស្រាវជ្រាវជាច្រើនដែលបង្ហាញថាមានជនរងគ្រោះជាច្រើនដែលបន្តមានបញ្ហាសុខភាព។ ជនរួចជីវិតមួយចំនួនបានរៀបរាប់ពីបញ្ហាសុខភាពរយៈពេលវែងដែលកំពុងបន្តមានបន្ទាប់ពីការជួញដូរនោះ ដោយពួកគាត់មិនបានទទួលជំនួយបន្តទៀត។

**ការគាំទ្រសុខភាពផ្លូវចិត្ត**សម្រាប់ជនរួចជីវិតគឺមានតិចតួចបំផុត។ អ្នកគ្រប់គ្រងករណីជាធម្មតាត្រូវបានបណ្តុះបណ្តាលអំពីការប្រឹក្សាយោបល់ជាមូលដ្ឋានប៉ុណ្ណោះ ហើយធ្វើការបញ្ជូនបន្តចំពោះករណីធ្ងន់ធ្ងរ។ អ្នកផ្តល់សេវាបានធ្វើការរំលឹកឡើងវិញថា ការបញ្ជូនជនរួចជីវិតអោយទទួលយកសេវាបន្ត ពិតជាមានសារៈសំខាន់ណាស់ក្នុងការជួយដល់ពួកគេអោយមានភាពប្រសើរឡើង។ ទោះជាយ៉ាងណាក៏

ដោយ ក៏អ្នកគ្រប់គ្រងករណី តែងតែមិនអាចសម្គាល់ឃើញបញ្ហាសុខភាពផ្លូវចិត្ត ឬធ្វើការបញ្ជូនទៅរកសេវានេះទេ។ ជាងនេះទៅទៀត ប្រទេសកម្ពុជាមានអ្នកជំនាញផ្នែកសុខភាពផ្លូវចិត្តតិចតួចណាស់ហើយ ជាធម្មតាជនរួចជីវិតត្រូវមានលទ្ធភាព និង
ឆន្ទៈក្នុងការធ្វើដំណើរទៅកាន់ទីប្រជុំជនដើម្បីព្យាបាល។ មានជនរួចជីវិតតិចតួចប៉ុណ្ណោះដែលមានចំណេះដឹង ឬធនធានផ្សេងទៀតដើម្បីធ្វើការនេះដោយគ្មានការគាំទ្រពីអ្នក
ផ្តល់សេវា។ ជនរួចជីវិតមួយចំនួនត្រូវបានអញ្ជើញឱ្យចូលរួមដំណើរកំសាន្តដកថយមួយរយៈជាមួយនឹងជនរងគ្រោះដទៃទៀត ប៉ុន្តែមិនមែនទាំងអស់គ្នាសុទ្ធតែទទួលបានឱកាសនេះទេ។ មិនមានក្រុមគាំទ្រដែលមានស្រាប់ សម្រាប់ជនរងគ្រោះជាបុរសឡើយ។

**ការគ្រប់គ្រងករណីរយៈពេលវែង និងការគាំទ្រសម្រាប់សិទ្ធិអំណាចសេដ្ឋកិច្ច-** ជនរួចជីវិតដែលទទួលបានជំនួយដ៏ពេញលេញបំផុត គឺអ្នកទាំងឡាយណាដែលត្រូវបានបញ្ជូនបន្តទៅអង្គការមួយក្នុងចំណោមអង្គការចំនួនបួន ដែលផ្តល់នូវការគ្រប់គ្រងករណីរយៈពេលវែង។ អង្គការទាំងនេះបានចាត់ចែងអ្នកគ្រប់គ្រងករណីអោយកាន់ករណីរបស់ជនរួចជីវិតម្នាក់មួយ (ដែលជាទូទៅហៅថា មន្ត្រីសមាហរណកម្ម) ដែលទទួលខុសត្រូវសម្រាប់ការជួយសម្រួលការគាំទ្រដល់តម្រូវការរបស់ជនរងគ្រោះ ។ អ្នកគ្រប់គ្រងករណីត្រូវបានបណ្តុះបណ្តាលអំពីជំនាញពិគ្រោះបញ្ហាកម្រិតមូលដ្ឋាន និងដើម្បីជួយធ្វើការបញ្ជូនជនរួចជីវិតទាំងនោះទៅទទួលយកសេវាផ្សេងទៀត។ មួយផ្នែកធំនៃតួនាទីរបស់មន្ត្រីទាំងនោះ គឺជួយសម្របសម្រួលអោយមានការគាំទ្រផ្នែកសិទ្ធិអំណាចសេដ្ឋកិច្ច។ ចំណុចនេះពាក់ព័ន្ធទៅនឹងការបញ្ជូនទៅទទួលវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ការគាំទ្រដល់ការបង្កើតអាជីវកម្មខ្នាតតូចមួយ ឬជាម្តងម្កាលគឺរកការងារអោយធ្វើ។ ការជួយទាំងនេះអាចមានរយៈពេលរហូតដល់ទៅពីរឆ្នាំ ឬយូរជាងនេះ។ ការគ្រប់គ្រងករណីរយៈពេលវែងបានជួយដល់ជនរួចជីវិតមួយចំនួនអោយមានស្ថេរភាពសេដ្ឋកិច្ច ទទួលបានការជឿជាក់លើខ្លួនឯង ឬការយកឈ្នះ លើបញ្ហាសុខភាពផ្លូវចិត្ត។ ទោះជាយ៉ាងណាក៏ដោយ ក៏បញ្ហាជាច្រើនធ្វើអោយប៉ះពាល់ដល់គុណភាពនៃការផ្តល់ជំនួយរយៈពេលវែង។ ធនធានដែលនៅមានកម្រិត គឺជាឧបសគ្គដល់ការផ្តល់ការគាំទ្ររបស់អ្នកគ្រប់គ្រងករណី ជាពិសេសរូបភាពនៃការរីករាលដាលនៃជនរួចជីវិតដែលមាននៅតាមតំបន់ភូមិសាស្ត្រផ្សេងៗគ្នាទូទាំងប្រទេស ។ ការពន្យារពេលក្នុងការជួយ អាចបណ្តាលអោយជនរួចជីវិតទាំងនោះបង្ខំចិត្តធ្វើចំណាកស្រុកសារជាថ្មី។ ការរក្សាទំនាក់ទំនងជាមួយជនរងគ្រោះដែលចល័តខ្លាំងពេកមានការលំបាកយ៉ាងសម្បើមផងដែរ។ លើសពីនេះទៅទៀត វគ្គបណ្តុះបណ្តាលដែលអ្នកគ្រប់គ្រងករណីបានទទួល មិនបានជួយឱ្យពួកគាត់អាចសម្គាល់ឃើញនូវតម្រូវការស្មុគស្មាញជាច្រើនដែលពួកគាត់អាចជួបប្រទះនោះទេ។ មូលនិធិក៏មានកំណត់ផងដែរ គឺមានម្ចាស់ជំនួយពីរ រឺក៏បីប៉ុណ្ណោះដែលមាន

ឆន្ទៈក្នុងការផ្តល់មូលនិធិលើការចំណាយដ៏ខ្ពស់សម្រាប់ការ(សមាហរណកម្ម)រួមបញ្ចូលគ្នារយៈពេលវែង។

## ការគាំទ្រសម្រាប់ការផ្តល់សិទ្ធិអំណាចផ្នែកសេដ្ឋកិច្ចក៏មានបញ្ហាប្រឈមមួយចំនួនដែរ:

- ការជួយ ពេលខ្លះមិនសមស្របទៅនឹងបរិបទរបស់ជនរួចជីវិត ឬកង្វះនៃការតាមដានបានជះផលប៉ះពាល់ជាអវិជ្ជមានដល់ការគាំទ្រ។
- ជនរួចជីវិតប្រឈមមុខនឹងឧបសគ្គក្នុងការទទួលយកការបណ្តុះបណ្តាលជំនាញជាពិសេសគឺមិនមានលទ្ធភាពក្នុងការរកប្រាក់ចំណូលក្នុងអំឡុងពេលទទួលការបណ្តុះបណ្តាល
- ទោះបីជាពួកគេធ្វើការប្រកបរបរដោយខ្លួនឯង "ដោយជោគជ័យ" ក៏ដោយ ក៏ពួកគេនៅតែរកបានប្រាក់ចំណូលបានតិចតួច ហើយពួកគេនៅតែងាយរងគ្រោះដោយសារការប្រែប្រួលលើទីផ្សារ ហើយទំនងជានៅតែធ្វើចំណាកស្រុកសារជាថ្មី ។
- ការផ្តល់ជំនួយត្រូវបានផ្តោតជាសំខាន់ស្ទើរគ្រប់ករណី ទៅលើផ្ទះក្នុងសហគមន៍ ទោះបីជាការបង្កើតប្រាក់ចំណូលនៅក្នុងបរិបទនោះមិនមានភាពប្រាកដនិយមក៏ដោយ។ វាមានការពិចារណាតិចតួចណាស់អំពីជម្រើសផ្សេងនៃសមាហរណកម្ម ដូចជារកការងារអោយធ្វើ ឬប្រកបរបរដោយខ្លួនឯងនៅក្នុងសហគមន៍ថ្មីមួយ។

ជនរួចជីវិតជាច្រើនបានធ្វើចំណាកស្រុកម្តងទៀតដោយសារតែការគាំទ្រផ្នែកសេដ្ឋកិច្ចត្រូវបរាជ័យ។ មានឱកាសសម្រាប់ការច្នៃប្រឌិតនៅក្នុងការគាំទ្រផ្នែកសេដ្ឋកិច្ច ជាពិសេសដើម្បីស្វែងយល់ពីភាពទូលំទូលាយនៃការប្រកបរបរដោយខ្លួនឯង  និងជម្រើសនៃវគ្គបណ្តុះបណ្តាល ការមានការងារធ្វើនៅឯសហគមន៍ រឺនៅកន្លែងផ្សេង និងជម្រើសនៃការរួមបញ្ចូលផ្សេងទៀត ដោយមានការគាំទ្រជនរួចជីវិតក្នុងការធ្វើចំណាកស្រុកដោយសុវត្ថិភាពទៅកាន់សហគមន៍មួយដែលមានឱកាសការងារកាន់តែប្រសើរ។

# អនុសាសន៍

## សម្រាប់រដ្ឋាភិបាលកម្ពុជា

ក. បង្កើនថវិកាប្រតិបត្តិការរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីក្រសួងអាចដើរតួនាទីកាន់តែធំក្នុងការជួយលើការ(សមាហរណកម្ម)រួមបញ្ចូល។

ខ. កែលម្អការត្រួតពិនិត្យនៅឯព្រំដែន។ ណែនាំអំពីចំណុចគោលដៅនៃ និរទេសជនដែលរាយការណ៍ថាកាលពីមុនពួកគេបានធ្វើការនៅលើទូកនេសាទ។

គ. ធ្វើបច្ចុប្បន្នភាពលើកម្មវិធីបណ្តុះបណ្តាលសម្រាប់មន្ត្រី និងប៉ូលីសអន្តោប្រវេសន៍កម្ពុជាដើម្បីអោយពួកគាត់អាច (១) បញ្ជូនជនរួចជីវិតដែលត្រូវបានកំណត់អត្តសញ្ញាណទាំងអស់ ទៅឱ្យអ្នកផ្តល់ជំនួយដើម្បីផ្តល់សេវាគ្រប់គ្រងករណី និង (២) ប្រជែងនឹងគំនិតយល់ខុសថាបុរសមិនមែនជាជនរងគ្រោះនៃការជួញដូរមនុស្ស។

ឃ.

បន្ថែមធនធានដល់ ស្ថានទូត និងស្ថានកុងស៊ុល - អាចបង្កើតជា អនុព័ន្ធការងារ

- ដើម្បីបង្កើនល្បឿនការធ្វើមាតុភូមិនិវត្តន៍ និងដើម្បីដើរតួនាទីយ៉ាងសំខាន់ក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ។ ផ្តល់អាទិភាពចំពោះ ប្រទេសម៉ាឡេស៊ី និងឥណ្ឌូនេស៊ី។

ង. កែលម្អភាពងាយស្រួលនៅតាមច្រកព្រំដែនដែលមានសុវត្ថិភាពឧទាហរណ៍ការបំពេញឯកសារលឿនរហ័ស និងមានតម្លៃថោកដែលអាចទទួលយកបាន។

## សម្រាប់អ្នកផ្តល់សេវាជួយសង្គ្រោះ

### ការកំណត់អត្តសញ្ញាណ

ក. សំរបសំរួលការប្រមូលទិន្នន័យ តាមអង្គការនានាទូទាំងប្រទេសក្នុងគោលបំណងពិនិត្យតាមដានអោយបានត្រឹមត្រូវលើនិន្នាការនៃកំណត់អត្តសញ្ញាណ។

ខ. ផ្តួចផ្តើមការផ្សព្វផ្សាយជាភាសាខ្មែរនៅតាមកំពង់ផែក្រៅប្រទេសដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះ ហើយតភ្ជាប់ ពួកគេទៅនឹងការផ្តល់ជំនួយសង្គ្រោះ។

គ. បង្កើតបញ្ជីជនជាតិខ្មែរដែលបាត់ខ្លួន

ឃ. តស៊ូមតិដល់រដ្ឋាភិបាលប្រទេសគោលដៅដើម្បីត្រួតពិនិត្យរកជនរងគ្រោះក្នុងចំណោមនិរទេសជន ជនជាប់ឃុំ និងប្រជាជនចំណាកស្រុកទូទៅ ជាពិសេសសម្រាប់អ្នកទាំងឡាយណាដែលធ្វើការលើនាវានេសាទ។

### ជំនួយក្នុងការធ្វើមាតុភូមិនិវត្តន៍

ក. តស៊ូមតិសម្រាប់ក្រសួងការបរទេសដើម្បីបង្កើនធនធានស្ថានកុងស៊ុលកម្ពុជាជាបន្ទាន់ដើម្បីបង្កើនល្បឿននៃការវិលត្រឡប់នៃជនរងគ្រោះដែលត្រូវបានកំណត់អត្តសញ្ញាណ។

ខ. បង្វិលសងប្រាក់ដល់ក្រុមគ្រួសារដែលបានចំណាយប្រាក់ផ្ទាល់ខ្លួនក្នុងការធ្វើដំណើរត្រឡប់មកវិញរបស់ជនរងគ្រោះ ក្នុងគោលបំណងដើម្បីរំដោះក្រុមគ្រួសាររបស់ពួកគេអោយរួចផុតពីបំណុល។

## ការទទួលស្វាគមន៍នៅក្នុងប្រទេសកម្ពុជា និងជំនួយការមូលដ្ឋាន

ក. យោងតាមបទដ្ឋាននៃការអនុវត្ត គេត្រូវបញ្ជូនជនរួចជីវិតណាដែលមានបំណងចង់ទទួលយកនូវជំនួយពីអង្គការដែលផ្តល់នូវការគ្រប់គ្រងករណីរយៈពេលវែងមួយ។ ប្រសិនបើជនរួចជីវិតមិនមានតម្រូវការច្បាស់លាស់នៅពេលមកដល់ សូមលើកទឹកចិត្តឱ្យពួកគាត់ធ្វើការភ្ជាប់ទំនាក់ទំនងក្នុងករណីដែលពួកគេមានតម្រូវការនាពេលអនាគត

ខ. កែលម្អ ឯកជនភាពក្នុងអំឡុងពេលពិធីទទួលពួកគេនៅរាជធានីភ្នំពេញ។ ការពារជនរងគ្រោះពីប្រព័ន្ធផ្សព្វផ្សាយ។ ប្រឆាំងចំពោះគំនិតមិនត្រឹមត្រូវដែលថា ជនរងគ្រោះជាបុរសមិនមានការភ័យខ្លាចខាងសុវត្ថិភាពទេ។

គ. សូមគិតអំពីឱកាសនៃការប្រមូលផ្តុំ ជនរួចជីវិតមួយរយៈខ្លីក្នុងការចែករំលែកព័ត៌មានអំពីសុខភាពផ្លូវចិត្ត ការធ្វើចំណាកស្រុកដែលមានសុវត្ថិភាព ឬឱកាសការងារ។

## ការទទួលបានយុត្តិធម៌ និងសំណង

ក. ពង្រឹងភាពជាដៃគូដើម្បីបន្តករណីផ្លូវច្បាប់នៅក្នុងប្រទេសថៃ។

ខ. បន្តផ្តល់ការតស៊ូមតិ និងប្រាក់សំណងផ្លូវច្បាប់ ដើម្បីធ្វើអោយសិទ្ធិជនរង គ្រោះក្នុងការទទួលសំណងត្រូវបានទទួលស្គាល់។

## ការគ្រប់គ្រងករណីរយៈពេលវែង

ក. កែលម្អប្រព័ន្ធបញ្ជូន ដោយផ្តល់អាទិភាពដល់រាល់ការបញ្ជូនជនរួចជីវិត ទៅអោយអង្គការមួយដែលផ្តល់នូវការគ្រប់គ្រងករណីរយៈពេលវែង។ បណ្តុះបណ្តាលក្រុមអ្នកឆ្លើយតបដំបូងគេ និងអ្នកផ្តល់សេវាផ្សេងទៀតដើម្បីបញ្ជូនជនរួចជីវិតទាំងអស់ទៅទទួលសេវាគ្រប់គ្រងករណី។ ធ្វើបច្ចុប្បន្នភាពលើកម្មវិធីបណ្តុះបណ្តាអោយស្របតាមស្ថានភាពខាងលើ។

ខ. ការបង្កើនធនធានសម្រាប់ការគ្រប់គ្រងករណីដើម្បីធានាថាការគ្រប់គ្រងករណីអាច

ផ្តល់នូវការគាំទ្រដ៏ពេញលេញ និងទាន់ពេលវេលា។ កំណត់ចំនួនករណីជនរង គ្រោះដែលអ្នកគ្រប់គ្រងករណីធ្វើការជាមួយអោយបានហ្មត់ចត់។

គ. បណ្តុះបណ្តាលសមត្ថភាពអ្នកគ្រប់គ្រងករណី ដើម្បីអាចកំណត់ពីតម្រូវការ និងធ្វើការបញ្ជូនដោយត្រឹមត្រូវ ដើម្បីធ្វើការជាមួយក្រុមគ្រួសារ និងដើម្បីធ្វើការ ជ្រើសរើសនូវការគាំទ្រលើការពង្រឹងអំណាចសេដ្ឋកិច្ចដ៏ល្អបំផុតដែលសមទៅនឹងបរិបទ។

ឃ. ស្វែងរកជម្រើសថ្មីៗសម្រាប់ការរក្សាទំនាក់ទំនងជាមួយជនរួចជីវិត ឧទាហរណ៍ផ្តល់នូវការលើកទឹកចិត្តសម្រាប់ជនរួចជីវិតក្នុងការបន្តទំនាក់ទំនងជាមួយអ្នកផ្តល់សេវា។

ង. ត្រៀមរៀបចំសម្រាប់ជនរួចជីវិតដែលចំណាកស្រុកជាយថាហេតុឡើងវិញដោយការកសាងបណ្តាញដៃគូបញ្ជូនបន្តពេញប្រទេស និងនៅក្នុងប្រទេសថៃ។

ច. ស្វែងរកវិធីក្នុងការសំរបសំរួលជំនួយរយៈពេលវែងជាមួយនឹងអ្នកផ្តល់សេវា។ សូមពិចារណាចាប់ផ្តើមកិច្ចប្រជុំឡើងវិញជាទៀងទាត់ជាមួយអ្នកផ្តល់សេវា។

## ការគាំទ្រផ្នែកសុខភាព

ក. ធ្វើការស៊ើបអង្កេតជាក់ស្តែងលើកម្រិតការគាំទ្រសុខភាពបន្តដែលមានកំរិតទាបដែលបានផ្តល់ជូន បើធៀបទៅនឹងបញ្ហាសុខភាពដែលបានចងក្រងជាឯកសារជាលក្ខណៈសិក្សា។

ខ. ពង្រីកវិសាលភាពនៃការវាយតម្លៃសុខភាពបឋម។

## ការគាំទ្រផ្នែកសុខភាពផ្លូវចិត្ត

ក. ស្វែងរកមធ្យោបាយដើម្បីកាត់បន្ថយឧបសគ្គដល់បុរសក្នុងការទទួលយកការគាំទ្រផ្នែកសុខភាពផ្លូវចិត្ត ដូចជាការដាក់បញ្ចូលសមាសភាគសុខភាពផ្លូវចិត្តចូលទៅក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្តល់ជូននូវការពិគ្រោះបញ្ហាតាមទូរស័ព្ទ ចែករំលែកការអប់រំសុខភាពផ្លូវចិត្តជាមូលដ្ឋាននៅពេលមកដល់ដំបូង ឬការបង្ហាញពីសម្រង់មតិរបស់ជនរួចជីវិតដែលបានអោយតម្លៃលើការជួយសង្គ្រោះ។

ខ. ធ្វើបច្ចុប្បន្នភាពលើកម្មវិធីបណ្តុះបណ្តាសម្រាប់អ្នកគ្រប់គ្រងករណីដើម្បីបង្កើនលទ្ធភាពឱ្យពួកគេអាចកំណត់អត្តសញ្ញាណ តម្រូវការសុខភាពផ្លូវចិត្ត និងការយល់ពីវិធីសាស្រ្តដ៏មានប្រសិទ្ធិភាពក្នុងការធ្វើការជាមួយបុរស។

គ. ស្វែងយល់ពីសក្តានុពលនៃក្រុមជួយខ្លួនឯង ឬការគាំទ្រពីក្រុមផ្សេងទៀត។ ផ្តល់នូវការដើរកំសាន្តដកថយជាក្រុមធំសំរាប់ជនរួចជីវិតទាំងនោះ។

ឃ. តស៊ូមតិសម្រាប់ការអភិវឌ្ឍរួមនៃការផ្តល់សេវាសុខភាពផ្លូវចិត្តនៅក្នុងប្រទេសកម្ពុជា។

## ការគាំទ្រដល់ក្រុមគ្រួសារ

ក. តាមរយៈជំនួយទាំងអស់សំរាប់ជនរួចជីវិត គួរពិចារណារកវិធីដើម្បីគាំទ្រដល់តម្រូវការរបស់សមាជិកគ្រួសារដែលពួកគាត់ជាជនរងគ្រោះបន្ទាប់។

ខ. សូមពិចារណាអំពីវិធីដើម្បីអប់រំដល់សមាជិកគ្រួសារអំពីសុខភាពផ្លូវចិត្ត។ ផ្តល់ការពិគ្រោះបញ្ហាជូនក្រុមគ្រួសារ ការគាំទ្រផ្នែកសុខភាព និងសុខភាពផ្លូវចិត្តដល់សមាជិកគ្រួសារ។ ពិចារណាបន្ថែមដំណើរកំសាន្តដល់ជនរួចជីវិត ដោយរួមបញ្ចូលទាំងសមាជិកគ្រួសាររបស់ពួកគេ។

គ. រួមបញ្ចូលសមាជិកក្រុមគ្រួសារក្នុងការផ្តល់សិទ្ធិអំណាចសេដ្ឋកិច្ច។

## ការគាំទ្រផ្នែកសិទ្ធិអំណាចសេដ្ឋកិច្ច

ក. សូមពិចារណាពីជម្រើសដែលបង្កើតប្រាក់ចំណូលទាំងក្នុង និងក្រៅសហគមន៍របស់ជនរួចជីវិត។ ប្រសិនបើជនរួចជីវិតនោះមានបំណងធ្វើ
ចំណាកស្រុក ត្រូវជួយពួកគេអោយធ្វើបានដោយសុវត្ថិភាព ហើយធ្វើការតាមដាននៅក្នុងទីតាំងថ្មីនោះ។

ខ. បង្កើតឱ្យមានកម្មវិធីរកការងារដោយចងជាដៃគូជាមួយវិស័យឯកជន

គ. ប្រសិនបើជនរួចជីវិតជ្រើសរើសប្រកបរបរដោយខ្លួនឯង សូមធានាអោយបានថាផែនការអាជីវកម្មរបស់ពួកគេត្រូវនឹងតម្រូវការនៅក្នុងទីផ្សារក្នុងស្រុក។

ឃ. តម្រូវវគ្គបណ្តុះបណ្តាលវិជ្ជាជីវៈអោយស្របនឹងជំនាញដែលខ្វះខាត និងផ្តល់នូវជំនាញកាន់តែច្រើន នៅក្នុងវិស័យដែលកំពុងរីកចម្រើន។ កាត់បន្ថយឧបសគ្គនានាចំពោះការបណ្តុះបណ្តាលដោយផ្តល់កន្លែងស្នាក់នៅ ការធ្វើដំណើរ និងថ្លៃចាយវាយសម្រាប់សិក្ខាកាម។

ង. ស្វែងរកជម្រើសដើម្បីគាំទ្រដល់ថ្នាក់ភូមិ ឃុំ ឬដើម្បីគាំទ្រដល់ជនរួចជីវិតចំរុះដែលត្រូវបានគេដាក់អោយរស់នៅជាក្រុមជិតគ្នា។

ច. រៀបចំផែនការបំរុង ក្នុងករណីវិធីសាស្រ្តរកប្រាក់ចំណូលដែលបានគ្រោងទុកនោះបរាជ័យ។

## ការផ្តល់មូលនិធិ

ក. បង្កើនថវិកាជូនដល់ជនរួចជីវិតម្នាក់រហូតដល់ ២០០០ ដុល្លារអាមេរិក ឬក៏ច្រើនជាងនេះ ។

ខ. លើកទឹកចិត្តឱ្យម្ចាស់ជំនួយ ផ្តល់មូលនិធិដល់បុរសក៏ដូចជាស្ត្រី និងកុមារ។

គ. តស៊ូមតិអោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បង្កើនថវិកាប្រតិបត្តិការរបស់ខ្លួន ដើម្បីក្រសួងអាចដើរតួនាទីកាន់តែធំក្នុងការផ្តល់ជំនួយសមាហរណកម្ម។